# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...៤១៣...សសរ..

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមការងារអន្តរក្រសួងដើម្បីសិក្សានិមិត្តសញ្ញារាជធានី ខេត្ត

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើតក្រុមការងារអន្តរក្រសួងដើម្បីសិក្សានិមិត្តសញ្ញារាជធានី ខេត្ត ដែលមានសមាសភាពដូចខាងក្រោម ÷

| | |
|---|---|
| ១-តំណាងក្រសួងមហាផ្ទៃ | ប្រធាន |
| ២-តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| ៣-តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៤-តំណាងក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៥-តំណាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក.../ |

៦-តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក

៧-តំណាងក្រសួងទេសចរណ៍ សមាជិក

៨-តំណាងក្រសួងព័ត៌មាន សមាជិក

៩-តំណាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សមាជិក

១០-តំណាងក្រសួងធម្មការ និងសាសនា សមាជិក

១១-តំណាងរាជបណ្ឌិតសភាកម្ពុជា សមាជិក

១២-អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ សមាជិក

**ប្រការ ២.-**

ក្រុមការងារអន្តរក្រសួង មានភារកិច្ចដូចខាងក្រោម ÷

- ណែនាំរាជធានី ខេត្តឱ្យធ្វើការសិក្សា ស្រាវជ្រាវអំពីនិមិត្តសញ្ញានៃរាជធានី ខេត្តរបស់ខ្លួន
- ពិនិត្យ ផ្ដល់យោបល់ និងវាយតម្លៃលើខ្លឹមសារ និងអត្ថន័យនៃនិមិត្តសញ្ញារាជធានី ខេត្ត
- រៀបចំសេចក្ដីព្រាងលិខិតស្ដីពីការកំណត់និមិត្តសញ្ញារាជធានី ខេត្ត ដើម្បីក្រសួងមហាផ្ទៃចាត់ចែងតាមនីតិវិធី ។

**ប្រការ ៣.-**

ប្រធានក្រុមការងារអន្តរក្រសួងមានសិទ្ធិអញ្ជើញអនុប្រធាន និងសមាជិកក្រុមការងារអន្តរក្រសួង ឱ្យចូលរួមប្រជុំ តាមការចាំបាច់ ។

**ប្រការ ៤.-**

ការចំណាយផ្សេងៗក្នុងការបំពេញភារកិច្ចរបស់ក្រុមការងារអន្តរក្រសួងជាបន្ទុករបស់ក្រសួងមហាផ្ទៃ ។

**ប្រការ ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងព័ត៌មាន រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា រាជបណ្ឌិតសភាកម្ពុជា និងអគ្គនាយករដ្ឋបាលមូលដ្ឋានក្រសួងមហាផ្ទៃ ត្រូវអនុវត្តសេចក្ដីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០១០

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ